# ស្តង់ដារកម្ពុជា CS 005: 2003 Rev-1:2015

# សម្រាប់

# ទឹកត្រី ( Fish Sauce )

## ១. វិសាលភាព

ស្តង់ដារនេះ កំណត់អំពីការតម្រូវ អនាម័យ គ្រឿងផ្សំម្ហូបអាហារ ការវេចខ្ចប់ ការធ្វើស្លាកសញ្ញា ការយកគំរូផលិតផល ការធ្វើតេស្ត និងលក្ខណៈវិនិច្ឆ័យសម្រាប់ភាពអនុលោមសម្រាប់ទឹកត្រី។

ស្តង់ដារនេះមិនអនុវត្តចំពោះទឹកត្រីដែលផលិតតាមវិធីសាស្រ្តអ៊ីដ្រូសីលអាស៊ីដ។

## ២. និយមន័យ

និយមន័យខាងក្រោមនឹងត្រូវអនុវត្តសម្រាប់បំពេញគោលបំណងនៃស្តង់ដារនេះ៖

២.១ **ទឹកត្រី៖** ជាផលិតផលរាវគ្មានកករ មានរសជាតិប្រៃ និងត្រីបានមកពីការល្បើងនៃល្បាយត្រី និងអំបិល។

២.២ **ដំណើរការផលិត៖** ទឹកត្រី ត្រូវបានរៀបចំដោយល្បាយត្រី និងអំបិល ហើយត្រូវ បានធ្វើល្បើងក្នុងធុងឬអាងដែលប្រកបដោយអនាម័យបិតជិត ជាទូទៅដំណើរការល្បើង មិនតិចជាង៣ខែ។

២.៣ **ម្សៅជាតិដែក៖** សំដៅដល់សូដ្យូម អាយ៉រែន អ៊ីឌីធីអេ (Sodium Iron ethylenediaminetetra-acetate) ដែលមានរូបមន្ត NaFeEDTA ឬអាយ៉ននសាល់ហ្វេតបូកនិងស៊ីត្រាត (ដែលមានរូបមន្ត $FeSO_4$ + Citrate)។

២.៤ **សារធាតុខាងក្រៅ៖** ជាទឹកត្រីមិនត្រូវមានវត្តមានសារធាតុខាងក្រៅ ដូចជា ឆ្អឹងត្រី ស្រកាត្រី ធូលី ខ្សាច់...។

## ៣. សមាសធាតុផ្សំសំខាន់ៗ និងកត្តាគុណភាព

### ៣.១ វត្ថុធាតុដើម

៣.១.១ **ត្រី៖** ទឹកត្រីត្រូវបានផលិតពីត្រី ឬបំណែកត្រី ដែលមានល័ក្ខខ័ណ្ឌសមស្របសម្រាប់ការប្រើប្រាស់របស់មនុស្ស ។

៣.១.២ **អំបិល៖** ត្រូវប្រើប្រាស់អំបិលមានគុណភាពសម្រាប់ម្ហូបអាហារ និងអនុលោមតាមស្តង់ដារ CS 055:2007 សម្រាប់អំបិលបរិភោគ។

៣.១.៣ **ទឹក៖** ទឹកសម្រាប់ប្រើប្រាស់រៀបចំជាទឹកអំបិលត្រូវតែជាទឹកស្អាត។

### ៣.២ កត្តាគុណភាព

លក្ខណវិនិច្ឆ័យដោយញ្ញាណត្រូវបានទទួលយកផ្អែកលើលក្ខណៈខាងក្រៅ ក្លិន និងរសជាតិ ដូចខាងក្រោម៖

- លក្ខណៈខាងក្រៅ៖ ជាផលិតផលរាវ គ្មានកករ
- ក្លិន និងរសជាតិ៖ ទឹកត្រីត្រូវមានក្លិន និងរសជាតិសម្គាល់ផ្ទាល់នៃផលិតផលទឹកត្រី។

## ៤. ការតម្រូវ

### ៤.១ លក្ខណៈគីមី

ទឹកត្រីត្រូវតែថ្លា និងគ្មានកករ លើកលែងតែក្រាមនៃអំបិលសូដ្យូមក្លរួ (Sodium Chloride) នៅពេលដែលបានធ្វើតេស្ត។

ទឹកត្រីត្រូវតែមានលក្ខណៈគីមីស្របទៅតាមការចែងនៅក្នុងតារាង ១ ខាងក្រោម៖

<u>តារាង១</u> ៖ លក្ខណៈគីមី

| ល.រ | ការតម្រូវ | កម្រិតអនុញ្ញាត | វិធីសាស្ត្រធ្វើតេស្ត |
|---|---|---|---|
| ១ | ដង់ស៊ីតេធៀបនៅ ២៧/២៧ °C ± ២ °C អប្បបរមា | ≥១,២ | ប្រើឧបករណ៍ Hydrometer |
| ២ | pH | ៤.៥- ៦,៥ | AOAC 981:12 |
| ៣ | អំបិល (Sodium Chloride) គិតជា ក្រាម/ល អប្បបរមា | ≥២00 | AOAC 937.13 / 976.18/ 976.19 |
| ៤ | អាហ្សូតសរុប (Total Nitrogen) គិតជា ក្រាម/ល អប្បបរមា | ≥១០ | AOAC 944.25 |
| ៥ | គ្លុយតាមិក អាស៊ីដ/អាហ្សូតសរុប (Glutamic acid/total nitrogen ) | ០,៤ - ០,៦ | ៨.៦ |
| ៦ | អាហ្សូតអាស៊ីដអាមីណេ (Amino acid nitrogen) គិតជា ក្រាម/ល អប្បបរមា | ≥៤០% នៃអាហ្សូតសរុប | AOAC955.04, AOAC 2000 |
| ៧ | បរិមាណជាតិដែកសុទ្ធ គិតជា ម.លក្រាម/ល | ២៣០-៤៦០ | Spectrophometric |

### ៤.២ សារធាតុមន្ថែម

ទឹកត្រីអាចត្រូវបានបន្ថែមសារធាតុបន្ថែមដែលមានសារធាតុដូចមានក្នុងតារាង២ ខាងក្រោម៖

| ល.រ | ប៉ារ៉ាម៉ែត្រ | កម្រិតអនុញ្ញាត |
|---|---|---|
| ១ | តាត្រាត(Tartrates) អតិបរមា | ២០០ ម.លក្រាម/គ.ក្រ |
| ២ | ប៉ូតាស្យូមអាសេស៊ុលហ្វាម(Acesulfame K) អតិបរមា | ១០០០ ម.លក្រាម/គ.ក្រ |
| ៣ | សាក់ការ៉ូស អតិបរមា | ៤៥០ ម.លក្រាម/គ.ក្រ |
| ៤ | ការ៉ាមែល ៣-អាម៉ូញាក់ អតិបរមា | ៥០, ០០០ ម.លក្រាម/គ.ក្រ |
| ៥ | បង់សូអាតអតិបរមា | ១០០០ ម.លក្រាម/គ.ក្រ |
| ៦ | សូបាត អតិបរមា | ១០០០ ម.លក្រាម/គ.ក្រ |

## ៥. អនាម័យ

ដំណើរការនៃលើសំបកវេចខ្ចប់ទឹកត្រីត្រូវអនុវត្តឲ្យមានអនាម័យអនុលោមតាមស្តង់ដារកម្ពុជា CS 084:2010 ស្តីពីគោលការណ៍រួមនិងការតម្រូវរបស់អាស៊ាន សម្រាប់អនាម័យម្ហូបអាហារ និងស្តង់ដារកម្ពុជា CS 0067: 2007 ស្តីពីគោលការណ៍ទូទៅនៃអនាម័យម្ហូបអាហារ។

## ៦. ការដាក់ស្លាកសញ្ញា

ស្លាកសញ្ញាទឹកត្រីត្រូវអនុវត្តដោយយោងតាមស្តង់ដារ CS 001: 2000 ស្តីពី ការបិទស្លាកលើផលិតផលចំណីអាហារ CS 084 :2014 គោលការណ៍រួមរបស់អាស៊ាន និងការតម្រូវសម្រាប់ស្លាកសញ្ញាម្ហូបអាហារវេចខ្ចប់រួច។

៦.១ យ៉ាងហោចណាស់នៅលើសំបកវេចខ្ចប់នីមួយៗត្រូវមាន រូបភាព អក្សរឬសញ្ញា សំគាល់ច្បាស់លាស់ និងអាចអានបាននូវព័ត៌មាន ដូចខាងក្រោម ៖

១- ឈ្មោះផលិតផល "ទឹកត្រី"

២- ម៉ាក ប្រសិនបើមាន

៣- កម្រិតថ្នាក់

៤- ចំណុះសុទ្ធគិតជាលីត្រ ឬមីលីលីត្រ

៥- ឈ្មោះនិងអាសយដ្ឋានរបស់អ្នកផលិត ក្រុមហ៊ុន រោងចក្រ អ្នកវេចខ្ចប់ ឬអ្នកចែកចាយ

៦- ប្រទេសដើមនៃផលិតផល

៧- លេខឡូត៍

៨- កាលបរិច្ឆេទផលិត និងផុតកំណត់ប្រើប្រាស់

៩- សេចក្តីណែនាំអំពីការរក្សាទុក

ក្នុងករណីសរសេរជាភាសាបរទេស ត្រូវមានខ្លឹមសារដូចព័ត៌មានខាងលើ។ ចំពោះទឹកត្រីនាំចូលត្រូវមានសរសេរឬបិទបន្ថែមអក្សរខ្មែរដែលអាចទទួលយកបានដោយអ្នកប្រើប្រាស់។

ព័ត៌មានចាំបាច់ដែលត្រូវសរសេរជាភាសាខ្មែរ ត្រូវមានលក្ខណៈពេញលេញ និងត្រឹមត្រូវតាមខ្លឹមសារដូចព័ត៌មានខាងលើ ។

## ៧. ការយកគំរូផលិតផល

៧.១ **ឡូតិ៍៖** សំដៅដល់ទឹកត្រីឈ្មោះតែមួយដូចគ្នានៅក្នុងចង្កោមផលិតកម្ម ឬការផ្គត់ផ្គង់មួយលើក។

### ៧.២ ការតម្រូវទូទៅសម្រាប់ការយកគំរូផលិតផល

៧.២.១ **ទំហំគំរូផលិតផល ៖** ជាចំនួនដបឬធុងទឹកត្រី ដែលត្រូវបានយកចេញពីឡូតិ៍ផលិតផលមួយសម្រាប់ការធ្វើអធិការកិច្ច។

៧.២.២ គំរូផលិតផលត្រូវបានដកយកស្របទៅតាមផែនការយកគំរូផលិតផលដែលបានផ្តល់ឲ្យ ឬដកយកទៅតាមបច្ចេកទេសដែលមានតម្លៃស្មើ។

### ៧.៣ នីតិវិធីនៃការយកគំរូផលិតផល

៧.៣.១ គំរូផលិតផលត្រូវតែបានដកយកចេញដោយចៃដន្យពីឡូត៍ផលិតផលតែមួយដូចគ្នា ដោយអនុលោមទៅតាមទំហំគំរូផលិតផលដែលមានចែងក្នុងតារាង ៣។

៧.៣.២ ក្នុងករណីដែលផលិតផលត្រូវបានផ្គត់ផ្គង់មកជាធុង ត្រូវដកយកគំរូផលិតផលទឹកត្រីចំណុះ ១០០០ ម.ល ចេញពីគ្រប់ធុងនៃទំហំគំរូផលិតផលនីមួយៗ ដោយអនុលោមទៅតាមតារាង៣ ហើយចំណែកទឹកត្រីដែលនៅសល់ត្រូវបញ្ជូនត្រឡប់ទៅឱ្យរោងចក្រវិញ។

៧.៣.៣ ចំនួនគំរូផលិតផលដែលបានជ្រើសរើសដោយចៃដន្យចេញពីឡូត៍មួយត្រូវអនុលោមតាមតារាង៣ខាងក្រោម៖

<u>តារាង ៣</u>៖ ចំនួនគំរូផលិតផលដែលត្រូវបានជ្រើសរើស

| ចំនួនគំរូផលិតផលនៅក្នុងឡូត៍ (ដប ឬ ធុង) | | | ចំនួនគំរូផលិតផលដែលត្រូវជ្រើសរើស (ដប ឬ ធុង) |
|---|---|---|---|
| តិចជាង | | ១៥០ | ៣ |
| ១៥១ | ដល់ | ២៨០ | ៥ |
| ២៨១ | ដល់ | ៥០០ | ៨ |
| ៥០១ | ដល់ | ១២០០ | ១៣ |
| ១២០១ | ដល់ | ៣២០០ | ២០ |
| ៣២០១ | ដល់ | ១០០០០ | ៣២ |
| ច្រើនជាង | | ១០០០០ | ៥០ |

## ៨ . **ការធ្វើតេស្ត**

៨.១ គំរូផលិតផលនីមួយៗត្រូវតែបានធ្វើតេស្តទៅលើភាពថ្លា ក្លិន រសជាតិ និងពណ៌ដោយក្រុមអ្នកពិនិត្យយ៉ាងតិចចំនួន ៥នាក់ ដែលអ្នកទាំងនោះមានបទពិសោធន៍អំពីការពិនិត្យទឹកត្រី។ អ្នកពិនិត្យនីមួយៗត្រូវពិនិត្យផលិតផលតាមសមត្ថភាពរៀងៗខ្លួន ហើយឲ្យពិន្ទុសម្រាប់ចរិកលក្ខណៈនីមួយៗនៃទឹកត្រី។

៨.១.១ ភាពថ្លា ក្លិន និងរសជាតិនៃទឹកត្រីត្រូវបានធ្វើតេស្តដោយញាណ។

៨.១.២ ពណ៌ត្រូវបានវិនិច្ឆ័យតាមលេខក្រិតនៃឧបករណ៍វង្វាស់។

៨.១.២.១ សម្ភារៈដែលត្រូវប្រើ ៖

១. ចានព័រសឺឡែន

២. ស្លាបព្រាអ៊ីណុក។

៨.១.២.២ ពិន្ទុត្រូវតែបានកំណត់ដោយអនុលោមទៅតាមលក្ខណៈវិនិច្ឆ័យ ដែលមានចែងក្នុងតារាង ៤។

<u>តារាង ៤</u> ៖ ប្រព័ន្ធនៃការផ្តល់ពិន្ទុ

| ចរិកលក្ខណៈ | ការតម្រូវ | វិធីសាស្រ្ត | ពិន្ទុ |
|---|---|---|---|
| ក្លិន | ក្លិនឈ្ងុយធម្មជាតិដូចចរិតលក្ខណៈនៃទឹកត្រី | ដោយញាណ | ៥០ |
| រសជាតិ | ឆ្ងាញ់ | ដោយញាណ | ៤០ |
| ពណ៌ | ពណ៌ត្នោតក្រហមព្រឿងៗ | ស្តង់ដារកូដិច | ១០ |

### ៨.២ ដង់ស៊ីតេធៀប (Relative Density)

ដង់ស៊ីតេត្រូវតែបានវាស់នៅក្នុងសីតុណ្ហភាព២៧±២$^{0}$C ដោយប្រើឧបករណ៍ Hydrometer។

### ៨.៣ pH

pH ត្រូវតែបានវាស់ដោយប្រើឧបករណ៍ pH ម៉ែត្រ។

### ៨.៤ អំបិលសូដ្យូមក្លរួ (NaCl) ។

#### ៨.៤.១ ការរៀបចំគំរូផលិតផល

ត្រូវដកយកសមាសភាគស្មើគ្នានៃទឹកត្រីពីរដប ឬធុងនៃគំរូផលិតផលនីមួយៗឲ្យបានចំណុះសរុបមិនតិចជាង ១លីត្រ។ បន្ទាប់មកត្រូវកូរសមាសភាគផ្សំនៃគំរូផលិតផលឲ្យសព្វក្នុងកែវឬចានស្ងួតនិងស្អាត រួចដកយកមួយភាគនៃគំរូផលិតផលចុងក្រោយនេះទៅលាយជាមួយទឹកដែលមានសមាសភាគដប់ដង។

#### ៨.៤.២ នីតិវិធី

ដំណើរការតាមការពណ៌នាក្នុងសៀវភៅ AOAC (Method 937.09 AOAC 2000) ឬវិធីសាស្ត្រដែលមានតម្លៃស្មើ។

### ៨.៥ អាហ្សូតសរុប (Total Nitrogen)

ត្រូវយកសមាសភាគផ្សំនៃគំរូផលិតផលដែលបានរៀបចំក្នុងចំណុច ៨.៤.១ មកប្រើ និងធ្វើពិសោធន៍តាមវិធីសាស្ត្រ ដែលបានកំណត់ក្នុងសៀវភៅ AOAC (Method 955.04 ឬ AOAC 2000) ឬវិធីសាស្ត្រដែលមានតម្លៃស្មើ។

### ៨.៦ អាស៊ីដគ្លុយតាមិក/អាហ្សូតសរុប (Glutamic acid /total nitrogen )

អាស៊ីដគ្លុយតាមិកត្រូវតែបានកំណត់ ដោយការប្រើឧបករណ៍វិភាគអាស៊ីដអាមីណេ (amino acid Analyzer) បន្ទាប់មកតម្លៃលេខទទួលបានត្រូវចែកនឹងតម្លៃអាហ្សូតសរុប។

### ៨.៧ អាហ្សូតអាស៊ីដអាមីណេ (Amino acid nitrogen )

អាហ្សូតអាស៊ីដអាមីណេគឺជាការខុសគ្នាគិតជាក្រាមរវាងអាហ្សូតហ្វ័រម៉ាល់ដេអ៊ីដ (formaldehyde nitrogen) និងអាហ្សូតអាម៉ូញ៉ាក់ (ammoniacal nitrogen) ក្នុង១លីត្រទឹកត្រី។

#### ៨.៧.១ អាហ្សូតហ្វ័រម៉ាល់ដេអ៊ីដ ( formaldehyde nitrogen )

##### ៨.៧.១.១ ឧបករណ៍ដែលត្រូវប្រើ ៖ pH ម៉ែត្រ

##### ៨.៧.១.២ សូលុយស្យុង

ក- សូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីដ (Sodium hydroxide) 0,១ ម៉ូល/លីត្រ

ខ- សូលុយស្យុងហ្វ័រម៉ាល់ដេអ៊ីដ (Formaldehyde) ដែលបានលៃដាក់តម្រូវឱ្យបាន pH = ៩ ដោយប្រើសូដ្យូមអ៊ីដ្រុកស៊ីដ ( Sodium hydroxide )។

**៨.៧.១.៣ នីតិវិធី**

លៃដាក់តម្រូវផលិតផលគំរូដែលបានលាយរួចចំនួន ១០ម.ល ដែល pH = ៧ ដោយប្រើសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីដ។ បន្ថែមសូលុយស្យុងហ្វ័រម៉ាល់ដេអ៊ីដ (Formaldehyde) ចំនួន១០ម.ល រួចធ្វើអត្រាកម្ម (Titration) ជាមួយសូលុយស្យុង សូដ្យូមអ៊ីដ្រុកស៊ីដ រហូតទទួលបាន pH = ៩។

**៨.៧.១.៤ ការគណនា**

ត្រូវគណនារកអាហ្សូតហ្វ័រម៉ាល់ដេអ៊ីដ (formaldehyde nitrogen)តាមរូបមន្តខាងក្រោម៖

$$X = 14\ Y\ M$$

ដែល៖

X គឺជាបរិមាណនៃអាហ្សូតហ្វ័រម៉ាល់ដេអ៊ីដ (formaldehyde nitrogen) គិតជាក្រាម នៅក្នុង១លីត្រ នៃគំរូផលិតផល

Y គឺជាមាឌនៃសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីដ (Sodium hydroxide) គិតជា ម.ល ដែលបានប្រើក្នុងការអត្រាកម្ម (Titration)

M គឺជាកំហាប់នៃសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីដ (Sodium hydroxide) គិតជា ម៉ូល/លីត្រ។

**៨.៧.២ អាហ្សូតអាម៉ូញ៉ាក់ (Ammoniacal nitrogen)**

**៨.៧.២.១ សារធាតុជំនួយប្រតិកម្ម និងសូលុយស្យុងដែលត្រូវប្រើ៖**

១- ម៉ាញ៉េស្យូមអុកស៊ីដ (Magnesium oxide)

២- សូលុយស្យុងអាស៊ីដប័រិក (Boric acid) ៦,៥ ម៉ូល/លីត្រ( ៤ % តាមទម្ងន់ )

៣- សូលុយស្យុងអាស៊ីដស៊ុលហ្វួរិក ០,០៥ ម៉ូល /លីត្រ

៤- សារធាតុចង្អុលពណ៌ (Methyl red bromocresol- green)

(Methyl red and bromocresol-green ០,១% តាមទម្ងន់ ១:៥ )។

**៨.៧.២.២ នីតិវិធី**

ផ្ទេរ ៥០ម.ល នៃគំរូផលិតផលលាយរួច ចូលក្នុងកែវបាឡុងសម្រាប់បឹត (Distilled billon) ហើយបន្ថែមម៉ាញ៉េស្យូមអុកស៊ីដ (magnesium oxide) ចំនួន ៣ក្រាម និងទឹកបិតចំនួន ១០០ម.ល។ បឹតឲ្យអាម៉ូញ៉ាក់ភាយឡើង ហើយធ្លាក់ចូលក្នុងកែវបាឡុងមួយទៀតដែលចាំបឹតស្រូប (to suck in absorb) យកដែលក្នុងកែវនោះ មានផ្ទុកសូលុយស្យុងអាស៊ីដបូរិកចំនួន ៥០ម.ល និងដាក់សារធាតុចង្អុលពណ៌ មេទីលក្រហម

ប្រូម៉ូក្រេសូលបៃតង (Methyl red bromocresol green) ពី ៦ ទៅ ១០ ដំណក់រហូតទាល់តែមាឌសូលុយស្យុងនៅក្នុងកែវបឺតនៅសល់តែ ១ ភាគ ៤ នៃមាឌ ដើមរបស់វា។ ធ្វើអត្រាកម្មអាម៉ូញ៉ាក់ដែលបឺតបានដោយសូលុយស្យុងអាស៊ីដស៊ុល ហ្វួរិករហូតទាល់តែសូលុយស្យុងប្តូរពណ៌ពីបៃតងទៅជាប្រផេះ។

**៨.៧.២.៣ ការគណនា**

ត្រូវគណនាសមាសធាតុអាហ្សូតអាម៉ូញ៉ាក់ (Ammoniacal nitrogen) តាមរូបមន្តដូចខាងក្រោម ៖

$$X = 5.6\ Y\ M$$

ដែល ៖

X គឺជាបរិមាណនៃអាហ្សូតអាម៉ូញាក់ (Ammoniacal nitrogen) គិតជាក្រាមនៅក្នុង ១លីត្រ នៃគំរូផលិតផល

Y គឺជាមាឌនៃសូលុយស្យុងអាស៊ីដស៊ុលហ្វួរិក គិតជាម.លដែលបានប្រើក្នុងការធ្វើអត្រាកម្ម

M គឺជាកំហាប់នៃសូលុយស្យុងអាស៊ីដស៊ុលហ្វួរិក គិតជា ម៉ូល/លីត្រ៕